# កិច្ចព្រមព្រៀងគម្រោងការ

រវាង

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា

ជាមួយនឹង

មជ្ឈមណ្ឌលឯកសារកម្ពុជា

# សង្ខេបគម្រោងកម្មវិធី

- ឈ្មោះគម្រោង : ការអភិរក្សនិងអភិវឌ្ឍសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
- ស្ថាប័នអនុវត្តគម្រោង : សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
- អ្នកផ្តល់ជំនួយសំខាន់ៗ : មជ្ឈមណ្ឌលឯកសារកម្ពុជា
- ទីកន្លែងអនុវត្តគម្រោង : រាជធានីភ្នំពេញ
- រយៈពេលរបស់គម្រោង : ៣ ឆ្នាំ
- ថវិកាគម្រោងសរុបមាន : ៣៣៤០១.៥ ដុល្លារ
- ចំនួនបុគ្គលិកបរទេសបម្រើការក្នុងគម្រោងមាន : គ្មាន
- ចំនួនបុគ្គលិកខ្មែរបម្រើការក្នុងគម្រោងមាន : ៣ នាក់
- គោលដៅនៃកិច្ចសហប្រតិបត្តិការក្នុងគម្រោងមាន :

ជួយអភិរក្ស និងអភិវឌ្ឍសារមន្ទីរទួលស្លែង តាមរយៈ :

១) ការរៀបចំរូបថតមួយចំនួនដែលទាក់ទងនឹងកុមារដែលរួចជីវិតពីមន្ទីរ ស.២១ និង រូបភាព មន្ទីរស.២១ផ្សេងទៀត (ថតដោយកងទ័ពវៀតណាម)។

២) ការរៀបចំកន្លែងដាក់បញ្ចាំងខ្សែភាពយន្តឯកសារ ដែលទាក់ទងនឹងសារមន្ទីរ ក្រោយ ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ និងដាក់បញ្ចាំងស្លាយរូបថតចំនួន ៥កន្លែង។

៣) ការរៀបចំកន្លែងក្រោយអគារចំនួន ៣ គឺអគារ ខ.គ.ឃ សម្រាប់តាំងបាន់ណូរូបថត។

៤) ការបង្កើតបន្ទប់រៀន១បន្ទប់ សម្រាប់រំឮកឡើងវិញពីជីវិតក្នុងសម័យកម្ពុជាប្រជាធិប-តេយ្យ ដល់សិស្សមកពីសាលា ឬ ភ្ញៀវមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជ-សាសន៍ទួលស្លែង។

៥) ការរៀបចំពិព័រណ៍រូបថតនរកកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដោយដាក់តាំងតែ៤ផ្ទាំង ធំៗ និងពិព័រណ៍ពីរទៀត ដែលខូចខាតនៅពេលត្រូវទឹកភ្លៀង។

៦) ការដាក់តាំងរូបថតនៅបាន់ណូខាងមុខសារមន្ទីរឡើងវិញ (កន្លែងដាក់តាំង រូប ប៉ុល ពត ស្លាប់) ដោយយករូបថតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យទាំង៥នាក់ ដែលកំពុងជាប់ឃុំឃាំងសព្វថ្ងៃ។

៧) ការរៀបចំពិព័រណ៍ថ្មីចំនួន២ទៀតក្នុងមួយឆ្នាំ។

# ពណ៌នាពីកម្មវិធីគម្រោង

គម្រោងកម្មវិធីនឹងផ្តល់កិច្ចគាំទ្រដល់ការចងចាំ និងយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

គោលបំណងរបស់គម្រោង គឺធ្វើយ៉ាងណាជួយអភិរក្សសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

គម្រោងកម្មវិធីនឹងគ្របដណ្តប់លើរាជធានីភ្នំពេញ រីឯផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះរួមមាន :

**ក) ការចងចាំ :**

ការជួយរៀបចំឱ្យមាន ការតាំងរូបថត ការរៀបចំកន្លែងបញ្ចាំងខ្សែភាពយន្តឯកសារ ការរៀបចំរូបប៉ាន់ណូធំ ការបង្កើតបន្ទប់សម្រាប់រំឭកឡើងវិញពីជីវិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ រៀបចំពិព័រណ៍ឡើងវិញ នឹងជួយឱ្យជនរងគ្រោះ រួមទាំងមនុស្សជំនាន់ក្រោយចងចាំនូវ និងយល់ដឹងអំពីទុក្ខវេទនាដែលប្រជាជនកម្ពុជាបានទទួលនៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត។

**ខ) យុត្តិធម៌ :**

ការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះរាប់លាននាក់ តាមរយៈការផ្តល់ឯកសារ រូបថត បទសម្ភាសន៍ ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**គ) ការផ្សះផ្សា**

ការជួយឱ្យអ្នកមកទស្សនានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានស្វែងយល់អំពីរបបខ្មែរក្រហម អំពីសោកនាដកម្មរបស់ប្រជាជនកម្ពុជា ក្នុងគោលដៅជួយជំរុញឱ្យមានការផ្សះផ្សានៅកម្ពុជា។

**ឃ) ការផ្សព្វផ្សាយទូលំទូលាយ :**

ការជួយដល់សោភ័ណភាព ត្រូវតាមលក្ខណៈសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង រួមទាំងការទាក់ទាញកម្រិតខ្ពស់តាមលក្ខណៈបច្ចេកទេស។ ជារួមទាំងអស់នេះនឹងជួយដល់ការផ្សព្វផ្សាយដ៏ទូលំទូលាយ ទាំងក្នុងប្រទេស ទាំងលើឆាកអន្តរជាតិ។

## លក្ខខណ្ឌលម្អិត
## ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
## និង
## មជ្ឈមណ្ឌលឯកសារកម្ពុជា បានព្រមព្រៀងដូចខាងក្រោមនេះ

### មាត្រា ១
### លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ កិច្ចព្រមព្រៀងនេះគឺធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ទាំងការអនុវត្ត និងការវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោង ដើម្បីឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តកម្មវិធីត្រូវពិភាក្សាជាមួយនាយកដ្ឋានជំនាញរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

១.៣ កាលបរិច្ឆេទចាប់ផ្តើមគម្រោង គឺចាប់ពីខែមីនា ឆ្នាំ២០១១ ហើយនឹងបញ្ចប់ទៅវិញនៅខែកុម្ភៈ ឆ្នាំ២០១៤។

១.៤ ក្នុងភាពជាដៃគូការងារ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានឯកភាពគ្នាថា នឹងធ្វើការពិនិត្យឡើងវិញលើគម្រោងយ៉ាងតិច៣ខែមុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នារួចហើយ សេចក្តីសម្រេចរួមគ្នាមួយនឹងត្រូវធ្វើឡើងថាតើត្រូវបញ្ឈប់គម្រោងតាមពេលវេលាកំណត់ ឬក៏ស្វែងរកកិច្ចបន្តគម្រោងមួយរយៈបន្ថែមទៀត។

១.៥ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់ជាផ្លូវការដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈ-មណ្ឌលឯកសារកម្ពុជាសម្រាប់ជាមូលដ្ឋានក្នុងការធ្វើសហប្រតិបត្តិការក្នុងការងារ។

### មាត្រា ២
### មជ្ឈមណ្ឌលឯកសារកម្ពុជាបានព្រមព្រៀង :

២.១ អនុវត្តការងារដើម្បីសម្រេចនូវទិសដៅរបស់គម្រោងជាក់លាក់ដូចខាងក្រោម :

**ក)** រៀបចំរូបថតមួយចំនួនដែលទាក់ទងនឹងកុមារដែលរួចជីវិតពីមន្ទីរ ស.២១ និងរូបភាព មន្ទីរ ស.២១ផ្សេងទៀត (ថតដោយកងទ័ពវៀតណាម)។

ខ) រៀបចំកន្លែងដាក់បញ្ចាំងខ្សែភាពយន្តឯកសារដែលទាក់ទងនឹងសារមន្ទីរ ក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ និងដាក់បញ្ចាំងស្លាយរូបថតចំនួន ៥កន្លែង។

គ) រៀបចំកន្លែងក្រោយអគារចំនួន ៣ គឺអគារ ខ.គ.ឃ សម្រាប់តាំងតាំងពិព័ណ៍រូបថត។

ឃ) បង្កើតបន្ទប់រៀន១បន្ទប់សម្រាប់រំឭកឡើងវិញពីជីវិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សមកពីសាលា ឬភ្ញៀវមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

ង) រៀបចំពិព័រណ៍រូបថតនរកកម្ពុជាប្រជាធិបតេយ្យឡើងវិញ ដោយដាក់តាំងតែ៤ផ្ទាំងធំៗ និងពិព័រណ៍ពីរទៀតដែលខូចខាតនៅពេលត្រូវទឹកភ្លៀង។

ច) ដាក់តាំងរូបថតនៅចាំងណូខាងមុខសារមន្ទីរឡើងវិញ (កន្លែងដាក់តាំង រូប ប៉ុល ពត ស្លាប់) ដោយយករូបថតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យទាំង៥នាក់ ដែលកំពុងជាប់ឃុំឃាំងសព្វថ្ងៃ។

ឆ) រៀបចំពិព័រណ៍ថ្មីចំនួន២ទៀតក្នុងមួយឆ្នាំ។

ជ) ជួយបណ្តុះបណ្តាលមន្ត្រីជំនាញរបស់សារមន្ទីរលើការងារគ្រប់គ្រង និងរៀបចំសារមន្ទីរ។

២.២ សហការធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាដៃគូការងារដើម្បីទទួលបានលទ្ធផលកម្រិតអតិបរិមាក្នុងការផ្ទេរបច្ចេកទេស និងសមត្ថភាពគ្រប់គ្រងនិងធ្វើផែនការដល់មន្ត្រីរាជការក្រសួង។

២.៣ រាល់ការបោះពុម្ព ឬឯកសារទាំងឡាយណាដែលបានពីសមិទ្ធិផលរបស់គម្រោងនេះ ត្រូវដាក់ជូនក្រសួងផ្តល់យោបល់ រួចហើយនឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នារបស់មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

២.៤ ចូលរួមឱ្យបានទៀងទាត់នៅរាល់កិច្ចការប្រជុំនីមួយៗ តាមការអញ្ជើញរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោងដែលកំពុងដំណើរការព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាដើម្បីឈានទៅសម្រេចជោគជ័យតាមទិសដៅរបស់គម្រោង។

២.៥ គម្រោងថវិកាដែលបានអនុម័ត ត្រូវប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពតាមទិសដៅដូចបានកំណត់:

| *គម្រោងចំណាយ* | *ឆ្នាំ២០១១* | *ឆ្នាំ២០១២* | *ឆ្នាំ២០១៣* | *សរុប* |
|---|---|---|---|---|
| ចំណាយលើប្រាក់ខែបុគ្គលិកបរទេស | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ចំណាយសម្រាប់ការិយាល័យ | គ្មាន | គ្មាន | គ្មាន | គ្មាន |
| *សរុបចំណាយលើការគាំទ្រគម្រោង* | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ចំណាយគាំទ្រមន្ត្រីជំនាញរបស់ក្រសួង | គ្មាន | គ្មាន | គ្មាន | គ្មាន |

| | | | | |
|---|---|---|---|---|
| ចំណាយលើសិក្ខាសាលា | -- | -- | -- | -- |
| ចំណាយលើផ្គត់ផ្គង់សម្ភារៈបច្ចេកទេស | ៧៩៧៦ | ១២១៥៣ | ៥៧៥៦ | ២៥៨៨៥ |
| ចំណាយទៅលើបរិក្ខាបន្ទាប់បន្សំ | ៨០០ | ១១៣៦.៥ | ៤៥០០ | ៦៤៣៦.៥ |
| ចំណាយទៅលើមធ្យោបាយដឹកជញ្ជូន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ចំណាយទៅលើការជួសជុល និងថែទាំ | ៣៦០ | ៣៦០ | ៣៦០ | ១០៨០ |
| ចំណាយទៅលើការសាងសង់ថ្មី | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ចំណាយទៅលើជំនួយបន្ទាន់ | | | | |
| ឬ ចំណាយទៅលើការធានារ៉ាប់រង | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ផ្នែកសុខភាព | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ចំណាយទៅលើការវាយតំលៃគម្រោង | គ្មាន | គ្មាន | គ្មាន | គ្មាន |
| *សរុបចំណាយផ្ទាល់* | ៩១៣៦ | ១៣៦៤៩.៥ | ១០៦១៦ | ៣៣៤០១.៥ |
| *ថវិកាគម្រោងសរុប* | **៩១៣៦ ដុល្លារ** | **១៣៦៤៩.៥ ដុល្លារ** | **១០៦១៦ ដុល្លារ** | **៣៣៤០១.៥ ដុល្លារ** |

២.៦ ផ្តល់ឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នូវរបាយការណ៍ប្រចាំ ត្រីមាស ឆមាស និងឆ្នាំ ដោយផ្អែកលើប្រតិទិនប្រចាំឆ្នាំ រួមមាន :

- របាយការណ៍សកម្មភាព និងការរីកចម្រើនរបស់គម្រោង។
- បញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង។
- ការចំណាយថវិកាគម្រោង (តាមប្រភេទដូចបានចែងក្នុងតារាង)។
- ព័ត៌មានអំពីចំនួនបុគ្គលិកបរទេស និងបុគ្គលិកជាតិ ព្រមទាំងតួនាទីរបស់គេ។

## មាត្រា ៣

## ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមព្រៀង :

៣.១ ចាត់តាំងមន្ត្រីពីររូប ដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប (ថ្នាក់ក្រសួង) ឱ្យបំពេញការងារជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងនាមជាអ្នកសហការអនុវត្តគម្រោង ដើម្បីឱ្យសកម្មភាពគម្រោងអនុវត្តន៍ទៅមានប្រសិទ្ធិភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា អាចជួលបុគ្គលិកកម្ពុជាធ្វើការបានដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការឱ្យបុគ្គលិក និងទីប្រឹក្សាអង្គការដែលចូលរួមក្នុងសកម្មភាពគម្រោងដែលត្រូវបានទទួលស្គាល់តាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ សម្របសម្រួលតាមករណីសមស្របដើម្បីសុំឱ្យមានការលើកលែងពន្ធ និងអាករដល់ឧបករណ៍ និងសម្ភារៈដែលយកមកប្រើប្រាស់គាំទ្រឱ្យសកម្មភាពគម្រោង។

៣.៥ បង្កើនប្រសិទ្ធិភាព និងតម្លាភាពការងាររបស់អង្គភាពជំនាញនៅមូលដ្ឋាន ដែលគាំទ្រដោយគម្រោងនេះ ដោយធានាយ៉ាងណាឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជានឹងទទួលបានព័ត៌មានទាន់ពេលវេលាស្តីពីការប្រើប្រាស់ថវិកា និងសកម្មភាព។

៣.៦ ធានាថាក្រសួងនឹងជំរុញឱ្យអង្គភាពជំនាញ ធ្វើការប្រាស្រ័យទាក់ទងឱ្យបានជិតដិតជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយកសាងផែនការ ការគ្រប់គ្រង និងដោះស្រាយបញ្ហា។

៣.៧ រាល់សំណើផ្សេងៗពីមជ្ឈមណ្ឌល នឹងត្រូវបានផ្តល់ចម្លើយពីក្រសួងវិញជាលាយលក្ខណ៍អក្សរ។

## មាត្រា ៤

## ល័ក្ខខ័ណ្ឌរួម

៤.១ ប្រធានគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ស៊ីរិ សាវីណា និង សើ សាយ្យាណា) ដែលបានជ្រើសតាំងជាតំណាងផ្លូវការដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងត្រូវបានផ្តល់សិទ្ធិជាតំណាងអង្គការរបស់ខ្លួនដើម្បីធ្វើការជាមួយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក នឹងចុះហត្ថលេខាដោយភាគីទាំងពីរ បន្ទាប់ពីបានពិចារណារួចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានគេបញ្ចប់ក្នុងស្ថានភាពបន្ទាន់តាមការសម្រេចរួមគ្នាមួយរវាងតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោយពីបានពិគ្រោះគ្នា និងពិចារណារួចរាល់ហើយ។

៤.៤ មជ្ឈមណ្ឌលឯកសារកម្ពុជា មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះ ក្រោយពីបានពិភាក្សាជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រសិនជាគេពិនិត្យឃើញថា គ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ដោយសង្គ្រាម ដោយអរិភាព ឬដោយការរំខានធ្ងន់ធ្ងរណាមួយ។

៧

៤.៥ បន្ទាប់ពីបានពិភាក្សាជាមួយអង្គការរួច ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងស្នើឱ្យអង្គការបញ្ឈប់ការងារចំពោះបុគ្គលិកណា ដែលត្រូវបានគេវិនិច្ឆ័យថាធ្វើឱ្យខូចកិត្តិយសក្រសួង បានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ ប្រសិនជាមានសំណើបែបនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវអនុវត្តន៍តាមដំណើរការសមគួរណាមួយ។

៤.៦ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះ ប្រសិនបើតំណាងផ្លូវការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានវិនិច្ឆ័យឃើញថា មិនបានបំពេញតាមមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ។

៤.៧ ប្រសិនបើគេរកឃើញថាមជ្ឈមណ្ឌលឯកសារកម្ពុជា មិនគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនព័ត៌មានដល់សាមីមជ្ឈមណ្ឌលនោះរួចមក។

៤.៨ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខា ហើយមានសុពលភាពរយៈពេល៣ឆ្នាំ ដូចមានចែងក្នុងចំណុច១.៤ នៃកិច្ចព្រមព្រៀងនេះ។

*កិច្ចព្រមព្រៀងនេះរៀបចំឡើងជាភាសាខ្មែរចំនួនពីរច្បាប់: ១ច្បាប់សម្រាប់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង១ច្បាប់ទៀតសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។*

បានចុះហត្ថលេខានៅរាជធានីភ្នំពេញ កម្ពុជា ថ្ងៃទី..០១...... ខែ..កក្កដា.. ឆ្នាំ ២០១១

**<u>ហត្ថលេខី</u>**

| | |
|---|---|
| តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | តំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា |
| ហត្ថលេខា | ហត្ថលេខា |
| ឃឹម សារិទ្ធ | |